ព្រះរាជាណាចក្រកម្ពុជា
សជណ-16-1.doc/ 21-07-17/សាល -បល-P.31

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
លេខ :

# សេចក្តីជូនដំណឹង
## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើស**បុគ្គលិក ចំនួន ០៣ រូប** ដូចខាងក្រោម ដើម្បីចូលបម្រើការងារនៅទីតាំងឃ្លាំងវត្តស្លែង ការិយាល័យផ្គត់ផ្គង់សម្ភារនិងដឹកជញ្ជូន នៃនាយកដ្ឋានលទ្ធកម្ម :

* - **លក្ខណៈសម្បត្តិបេក្ខជន** :

**១. បុគ្គលិកឃ្លាំងវត្តស្លែង** ចំនួន ០១ រូប :
- បេក្ខជនភេទប្រុស, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតវប្បធម៌ : បានបញ្ចប់ការសិក្សា សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ: Word-Excel
- ភាសាអង់គ្លេស : ចេះអាចប្រើការបាន ជាមធ្យម

**២. អ្នកបើកបររថយន្ត** ចំនួន ០១ រូប :
- បេក្ខជនភេទប្រុស, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E. III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតវប្បធម៌ : បានបញ្ចប់ការសិក្សា សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ឡើងទៅ និងមានប័ណ្ណបើកបររថយន្តប្រភេទ "ឃ២"

**៣. បុគ្គលិកអនាម័យ** ចំនួន ០១ រូប :
- បេក្ខជនទាំងពីរភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E. VII.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតវប្បធម៌ : បានបញ្ចប់ការសិក្សា សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ឡើងទៅ
- បេក្ខជន មានអាសយដ្ឋាន ស្ថិតនៅក្បែរទីតាំងឃ្លាំងវត្តស្លែង ប្រសិនបើលទ្ធផល ពិន្ទុប្រហាក់ប្រហែលគ្នា គឺត្រូវផ្តល់អាទិភាព ។

* - **ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជាបេក្ខជនត្រូវទាញយក(Download) ដោយផ្ទាល់ពីក្នុងគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជា ។**

* - **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

| | |
|---|---|
| - ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា | ចំនួន ០១ ច្បាប់ |
| - ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ | ចំនួន ០១ ច្បាប់ |
| - កិច្ចសន្យា សម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ | ចំនួន ០១ ច្បាប់ |
| - សលាកប័ត្របេក្ខជន | ចំនួន ០១ ច្បាប់ |

- លិខិតបញ្ជាក់ការសិក្សា ឬ ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ មានបញ្ជាក់ពីអាជ្ញាធរដែនដី ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងប័ណ្ណបើកបររថយន្ត (សម្រាប់អ្នកបើកបររថយន្ត) ចំនួន ០១ ច្បាប់

*- **ចំពោះបែបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធ នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម ។**

*- **ទីកន្លែងទទួលពាក្យ** : **នៅអគារ B ជាន់ទី១ ការិយាល័យបុគ្គលិក នៃអគ្គិសនីកម្ពុជា**
ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី**១**៤ ខែសីហា ឆ្នាំ២០១៧ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០ ។

*- **<u>ព័ត៌មានផ្សេងៗ</u>** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៧

ជ. **ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**
**អគ្គនាយករង**

**ឥវេង_គន្ធា**

**<u>បញ្ជាក់</u>**
- សេចក្តីជូនដំណឹងនេះ ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់ អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ " ។